Fo 10
M 13

មលប់បៃតង MLUP BAITONG
ព្រឹត្តិបត្រ
# បរិស្ថានខ្ញុំ
ចេញផ្សាយប្រចាំ ត្រីមាស (លេខ៨) ឆ្នាំទី៣ ខែមករា_មិនា ឆ្នាំ២០០៣

# រុក្ខជាតិឱសថធម្មជាតិ



គំនូរសិស្ស ភោគ សុខធឿន សាលាបឋមសិក្សាត្រពាំងក្រឡឹង



គំនូរសិស្ស ហាយ គីមសួគ៌ សាលាបឋមសិក្សាមហាសាំង



គំនូរសិស្ស ឈើវ ស៊ីណាក់ សាលាបឋមសិក្សាបន្ទាប់



គំនូរសិស្ស សុង ភារិទ្ធ សាលាបឋមសិក្សាត្រពាំងក្រឡឹង

ហោមាលក់

# អារម្ភកថា

**សួស្តី!** ប្អូនៗកុមារា កុមារីជាទីស្នេហា! តើព្រឹត្តិបត្របរិស្ថានខ្ញុំលេខ៨នេះនឹងមានអ្វីមកបង្ហាញប្អូនៗ? **បរិស្ថានខ្ញុំ** សូមនាំប្អូនៗឱ្យបានស្គាល់ពី **រុក្ខជាតិឱសថធម្មជាតិ**ដែលមាននៅក្នុងព្រឹត្តិបត្រនេះដោយបានចូលរួមចំណែកពីប្អូនៗ តាមរយៈការសរសេរជា សំនួរ កំណាព្យ រូបភាព ។ ដូចនេះសូមប្អូនៗយកចិត្តទុកដាក់តាមដានព្រឹត្តិបត្រដោយសប្បាយរីករាយ ។ ពេលក្រោយបរិស្ថានខ្ញុំនឹងបង្ហាញប្អូនៗពី **កុមារនិងបរិស្ថាន** ។ បរិស្ថានខ្ញុំមានជំនឿថា ប្អូនៗនឹងសរសេរ អត្ថបទខ្លី តែងកំណាព្យ សួរសំនួរ គូររូបភាពស្តីពី **កុមារនិងបរិស្ថាន** ដែលអាចផ្ញើតាមរយៈប្រអប់សំបុត្របរិស្ថានខ្ញុំនៅតាមសាលារបស់ប្អូនៗ ។

**មាតិកា**


១-អារម្ភកថា
២-អត្ថបទខ្លី
៣-ស្វែងយល់
៤-ល្បែងសិក្សា
៥-សំនួរ-ចំលើយ
៦-ទំព័រកំសាន្ត
៧-ល្បងប្រាជ្ញា
៨-កំណាព្យបរិស្ថាន
៩-សំនួរត្រិះរិះ


សូមប្អូនៗចូលរួមដាំ ថែរក្សា និងការពាររុក្ខជាតិឱសថធម្មជាតិ ដែលដុះនៅតាមសាលា និងសហគមន៍របស់ប្អូនៗ ឱ្យបានគង់វង្ស ទុកជាផលប្រយោជន៍សំរាប់ប្រើប្រាស់ទូទៅ ។

◄ សូមអរគុណ ►



គំនូរសិស្ស ជា សុខចាន់ សាលាបឋមសិក្សាត្រពាំងក្រឡឹង

**អត្ថបទខ្លី**

# រុក្ខជាតិឱសថធម្មជាតិ

**រុក្ខជាតិឱសថធម្មជាតិ** គឺជារុក្ខជាតិដែលគេអាចយកផ្នែកណាមួយរបស់វាមកធ្វើជាឱសថព្យាបាលជំងឺផ្សេងៗបាន ។ រុក្ខជាតិទាំងនោះមានដុះនៅក្នុងស្រុកយើងដែលមានលក្ខណៈជារុក្ខជាតិតូច ធំនិងរុក្ខជាតិវល្លិជាដើមដូចជា ស្មៅក្រវាញជ្រូក ប្រមោយដំរី ដើមធ្នា ស្លែង ស្តៅ គរ ត្របែក ឆ្កែស្រែង អំពិល វល្លិបណ្តូលពេជ្រ ផ្កាវំយោល ម្លូលពេជ្រ ប្រទាលផ្សេងៗ ...។ គេយករុក្ខជាតិទាំងនេះមកធ្វើថ្នាំព្យាបាលតាមប្រភេទជំងឺ ។ មើមក្រវាញជ្រូក ត្រូវនឹងជំងឺចុកឆ្អល់ សំបកនិងត្រួយត្របែកត្រូវនឹងជំងឺរាកមួល សំបកដើមធ្នា ត្រូវនឹងជំងឺគ្រុនពោះវៀន និងក្រពះ សំបក ស្លឹកស្តៅ សំបកគរ ត្រូវនឹងជំងឺគ្រុនក្តៅ មើមឆ្កែស្រែង ត្រូវនឹងរបួសត្រួយអំពិលផ្សំនឹងអំបិល ព្យាបាលជំងឺភ្នែកឡើងបាយ បណ្តូលពេជ្រ ដក់គន់ត្រូវនឹងសរសៃខ្ចី វល្លិកំបោរត្រូវនឹងឬសដូងបាត ( តាមទំលាប់ចាស់បូរាណតៗគ្នាមក) ។

ដូចនេះប្អូនគួរប្រើប្រាស់ឱសថធម្មជាតិនៅពេលមានជំងឺ ព្រោះជួយសន្សំប្រាក់គ្រួសារ ។ ប៉ុន្តែត្រូវចេះយកវាមកប្រើឱ្យសមហេតុផលដើម្បីឱ្យរុក្ខជាតិទាំងនោះអាចរស់នៅបានគង់វង្សយូរអង្វែង ។



គំនូររបស់ប្អូន ម៉ាង ង៉ែត សិស្សសាលាបឋមសិក្សា២ធ្នូ



គំនូររបស់ប្អូន ប៊ុន លីម សិស្សសាលាបឋមសិក្សាត្រពាំងអំពិល

ស្វែងយល់ ?

# អនិច្ចាដើមធ្នា

**ធ្នា** គឺជារុក្ខជាតិបន្លាមួយប្រភេទ មានដើមធំ ខ្ពស់ ខ្លឹមវារឹង។ រុក្ខជាតិនេះមានមែកច្រើន ស្លឹកវាល្អិតៗ។ ដើមធ្នាមានដុះគ្រប់ទីកន្លែងនៅក្នុងប្រទេសយើង។ គេអាចយកត្រួយខ្ចី ទៅធ្វើជាបន្លែបរិភោគបាន។ ដើមវាគេយកទៅធ្វើគ្រឿងសំនង់ផ្សេងៗ។ រីឯសំបកគេយកទៅធ្វើជាឱសថព្យាបាលជំងឺក្រពះ ឬគ្រុនពោះវៀន។ ប៉ុន្តែសព្វថ្ងៃរុក្ខជាតិធ្នានេះត្រូវបានទទួលរងការបំផ្លាញអស់ជាច្រើន ហើយឈានទៅរកការផុតពូជជាបណ្ដើរៗ។ ដោយសារតែការស្ទោះសំបកអស់ពីគល់ឬដើម អាចធ្វើឱ្យរុក្ខជាតិនេះងាប់បានព្រោះរុក្ខជាតិរស់បានដោយសារសំបករបស់វា។ បើយើងស្ទោះសំបកធ្នាឬរុក្ខជាតិផ្សេងទៀតមកធ្វើថ្នាំ រួចត្រូវយកដីមកលាបកន្លែងដែលស្ទោះនោះដើម្បីឱ្យវាដុះសំបកសារជាថ្មី។ ការធ្វើរបៀបនេះទើបរុក្ខជាតិធ្នា ឬរុក្ខជាតិផ្សេងទៀតមិនងាប់។ ដើម្បីជាប្រយោជន៍ទៅថ្ងៃមុខ យើងទាំងអស់គ្នាត្រូវចេះប្រើប្រាស់ និងចូលរួមថែរក្សាប្រភេទដើមធ្នា ឬរុក្ខជាតិផ្សេងទៀតឱ្យបានគង់វង្សទុកសំរាប់ធ្វើឱសថបន្តទៀត។






១~ចូរប្អូនរៀបលេខដាក់ក្នុងរង្វង់តាមជ្រុងត្រីកោណដោយលៃ យ៉ាងណាឱ្យផលបូកលេខតាមជ្រុង ទីមួយៗ នៃត្រីកោណស្មើនឹង ៩



១ ២

៣ ៤

៥ ៦

២~ចូរប្អូនៗរៀបស្រះ និងព្យញ្ជនៈឱ្យចេញជាពាក្យមួយមានន័យ ស្តាប់បានដែលជាឈ្មោះរុក្ខជាតិឱសថធម្មជាតិ៖

<u>ឧទាហរណ៍</u>៖ ល ម ព ្ល ្រ ុ ជ ៈ ម្លុលពេជ្រ

១- ្ក េ ា ស ៖ ............?

២- ា ្ន ធ ៖ ..............?

៣- ក រ ឈ ូ ័ ត ្ន ៈ ...............?

៤- ែ ែ ្រ ឆ ស ង ្ក ៖ ................?

# សំណួរ_ចំលើយ

**សំនួរៈ** ប្អូនស្រីឈ្មោះ ធុំ ចន្ទី សាលាបឋមសិក្សា ត្រពាំងអំពិល បានសួរថាៈ នៅពេលក្មេងមានជំងឺគ្រុនក្ដៅ គេយកឱសថបូរាណអ្វីសំរាប់ព្យាបាល?

**ចំលើយៈ** នៅពេលក្មេងកើតជំងឺគ្រុនក្ដៅ មានឱសថបូរាណច្រើនប្រភេទដែលគេយកមកព្យាបាល ដូចជា ផ្លែក្រូចឆ្មា ជីត្រចៀកជ្រូក ផ្លែម្រះ សំបក ដើម និងឫសស្វាយ ។

**សំនួរៈ** ប្អូនប្រុសឈ្មោះ ង៉ែត សាន សាលាបឋមសិក្សាដំណាក់ត្រាច បានសួរថាៈ តើរុក្ខជាតិឱសថធម្មជាតិ មាននៅឯណា?

**ចំលើយៈ** រុក្ខជាតិឱសថធម្មជាតិ មាននៅស្ទើរគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ហើយក៏មានផងដែរនៅ តាមគេហដ្ឋានរបស់យើង ។



គំនូររបស់ប្អូន ផាត់ ភក្ដី សិស្សសាលាបឋមសិក្សា

គំនូររបស់ប្អូន ចាន់ ផុនសារឹម សិស្សសាលាបឋមសិក្សាត្រពាំងក្រឡឹង



**សំនួរ:** ប្អូនស្រីឈ្មោះ ទឹម ចន្ទ័ សាលាបឋមសិក្សា ត្រពាំងអំពិល បានសួរថា: តើរុក្ខជាតិអ្វីខ្លះដែលគេចាត់ទុកជាឱសថបូរាណ?

**ចំលើយ:** រុក្ខជាតិដែលគេចាត់ទុកជាឱសថបូរាណមានស្ទើរគ្រប់រុក្ខជាតិទាំងអស់ តែរុក្ខជាតិទាំងអស់នោះវាព្យាបាលជំងឺទៅតាមប្រភេទផ្សេងៗគ្នា។

**សំនួរ:** ប្អូនប្រុសឈ្មោះ ឆាយ ផានី សាលាអនុវិទ្យាល័យមហាសាំង បានសួរថា: តើរុក្ខជាតិទាំងអស់សុទ្ធតែជាឱសថមែនឬទេ?

**ចំលើយ:** រុក្ខជាតិជាច្រើនជាឱសថ តែមិនគ្រប់ទាំងអស់នោះទេ គឺមានរុក្ខជាតិខ្លះក៏ជាថ្នាំពុលដែរ ។

**សំនួរ:** ប្អូនឈ្មោះ ស៊ួន ប៊ុនលាង សាលាបឋមសិក្សាត្រពាំងឱប បានសួរថា: ហេតុអ្វីបានជាគេត្រូវការរុក្ខជាតិឱសថធម្មជាតិ?

**ចំលើយ:** បានជាគេត្រូវការរុក្ខជាតិឱសថធម្មជាតិ ព្រោះគេប្រើវាសំរាប់ព្យាបាលជំងឺដូចជាថ្នាំពេទ្យដែរហើយចំណាយប្រាក់តិច និងមិនប៉ះពាល់សុខភាពទៀតផង ម៉្យាងទៀតស្ទើរគ្រប់ថ្នាំពេទ្យទាំងអស់ប្រើរុក្ខជាតិជាវត្ថុធាតុដើម។



គំនូររបស់ប្អូន ភាព បូណា សិស្សសាលាបឋមសិក្សា៧មករា

ចំពាក់កំសាន្ត

# ប្រយោជន៍នៃឱសថធម្មជាតិ




ថ្ងៃមួយ **ភយ** បានធ្វើដំណើរតាមដងផ្លូវហើយបានជួប **ក្ងុយ**

**ក្ងុយ:** **ភយ** តើឯងទៅណា?

**ភយ:** បាទ! ខ្ញុំទៅរកថ្នាំព្យាបាលជំងឺប្អូន។

**ក្ងុយ:** នែ៎! **ភយ** តើប្អូនឯងឈឺអ្វី?

**ភយ:** ប្អូនខ្ញុំលាប់កញ្ជ្រិល ក្ដៅស្ទើរសន្លប់ទៅហើយ។

**ក្ងុយ:** អូ! លាប់មែនរឺ? បើអញ្ចឹងខ្ញុំមានឱសថធម្មជាតិមួយ៉ាង គឺ **ប្រទាលកូនខ្លោត**។ ឯងយកទៅបុកលាយទឹកឆ្អិនឱ្យវាផឹកចុះ។

**ភយ:** អឺ! បើអញ្ចឹងខ្ញុំសុំបន្ដិច។

**ក្ងុយ:** បាទ! យកចុះនៅក្នុងសួនឯនោះ។

ព្រឹកព្រលឹមស្រាងៗ **ភយ** បានដើរមកផ្ទះ **ក្ងុយ** ដើម្បីថ្លែងអំណរគុណ។

**ភយ:** **ក្ងុយ!** ខ្ញុំសូមអរគុណដល់ឯងដែលបានឱ្យថ្នាំដល់ខ្ញុំ។ ឥឡូវប្អូនខ្ញុំជាហើយ ដោយមិនបាច់ប្រើលុយទៀតផង។

**ក្ងុយ:** យើងត្រូវចេះប្រើឱសថធម្មជាតិផង ព្រោះវាមិនចាំបាច់ចំណាយលុយកាក់ច្រើនទេ។

# ល្បែងប្រាជ្ញា

ចំលើយល្បែងប្រាជ្ញាព្រឹត្តិបត្រលេខ៧: ១-ខ្លែងសំរាប់បង្ហោះលេង ២-ចន្លុះ ៣-ម្លូ

១ រុក្ខាដុះក្បែរផ្លូវអ្នកផងដើរទៅហៅឯងឆ្លើយឯង។ តើជាអ្វី?

២ រុក្ខាមានឈ្មោះបីម៉ាត់លុបខាងដើមពីរព្យាង្គចាត់ទៅព្រះគង្គា។ តើជាអ្វី?

៣ រុក្ខជាតិបែកជាពីរ មច្ឆាទំមី លតា វណ្ណចុង។ តើជាអ្វី?

 ចំលើយនឹងមាននៅព្រឹត្តិបត្រ បរិស្ថានខ្ញុំ លេខ ៩

កំណាព្យបរិស្ថាន
បទកាកគតិ

# រុក្ខជាតិឱសថធម្មជាតិ

១- ដូនតាបានផ្តាំ    រុក្ខជាតិជាថ្នាំ    ត្រូវដាំបន្ត
រក្សាឱ្យគង់    សុខភាពបវរ    ថែឱ្យបានល្អ
កុំកាប់បំផ្លាញ ។

២- ឆ្កែស្រែងដក់គន់    បន្ទាល់ពងមាន់    ដើមផ្កាក្រវាញ
ក្តុកក្តុលរាំងភ្នំ    គ្រៀលស្វាអញ្ចាញ    ខ្ញុំសូមបង្ហាញ
ឱសថធម្មជាតិ ។

៣- ក្នុងព្រៃច្រើនណាស់    អ្នកចាំឱ្យច្បាស់    មានដើមវល្លិល្មៀត
វល្លិរលាយឈាម    ប៉ប្រកថែមទៀត    សុទ្ធតែរុក្ខជាតិ
សំរាប់កែរោគ ។

៤- ខ្លះដុះជិតផ្ទះ    សំបូរឥតខ្វះ    ឱសថគគោក
ផ្ទីប្រម៉ាត់ដី    ទៀបស្លឹកកន្ទ្រោប    ស្លឹកគត បំពោក
ជាថ្នាំត្រជាក់ ។



គំនូររបស់ប្អូន សេង ចន្ទ សិស្សសាលាបឋមសិក្សាត្រពាំងអំពិល



គំនូររបស់ប្អូន សន ធានី សិស្សសាលាបឋមសិក្សា

# សំនួរត្រិះរិះ ?



១- តើរុក្ខជាតិអ្វីខ្លះ ដែលអាចប្រើជាឱសថបាន?

............................................................................................................................................

............................................................................................................................................ ។

២- ចូរប្អូនៗគូសសញ្ញា ☑ នៅក្នុងពាក្យណាដែលប្អូនៗយល់ថារុក្ខជាតិនោះ គេអាចយកទៅធ្វើជាថ្នាំព្យាបាលផង និង សំរាប់ធ្វើជាអាហារផង ។

☐ ក្រវាញជ្រូក ☐ ប្រមោយដំរី ☐ ក្រសាំង ☐ ស្ដៅ

☐ ស្លែង ☐ ធ្នា ☐ ម្រុំ ☐ សង្កែ

៣- ចូរគូសសញ្ញាព្រួញពី ក ទៅ ខ ឱ្យបានត្រឹមត្រូវ ដើម្បីបញ្ជាក់ពីប្រយោជន៍នៃដើមស្ដៅ ។

| ក | | ខ |
|---|---|---|
| ស្លឹក<br>ត្រួយ<br>ផ្កា<br>ផ្លែ<br>សំបក<br>ឫស | | ថ្នាំ<br><br>អាហារ |



គំនូរសិស្ស ឈុន ស្រីឡែន សាលាបឋមសិក្សា ៧មករា



គំនូរសិស្ស យ៉ាង ថាច សាលាបឋមសិក្សាត្រពាំងក្រឡឹង

# ពត៌មាន!

## សកម្មភាពក្លឹបបរិស្ថាន



សកម្មភាពការបង្រៀនបរិស្ថាន នៅសាលាបឋមសិក្សា ជាំសង្កែ



សកម្មភាពសិស្សដាំកូនឈើនៅសាលាបឋមសិក្សាមិត្តភាពកម្ពុជា-ជប៉ុន

Mlup Baitong PO Box 2510. Phnom Penh 3. Cambodia.
Tel/Fax: ++855-23-214-409. Mobile: ++855-12-909-502. e-mail: mlup@bigpond.org.kh